# គោលសំខាន់ក្នុងសិង្គាលកសូត្រ

# (អរិយវិន័យ)

*( សុត្តន្តបិដក ទីឃនិកាយ លេខ ១៩ ទំព័រ ៦៧-៩៣)*

*ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងនូវធម៌បិទបាំងទិសទាំង ៦ ប្រតិបត្តិ ដើម្បីជំនះក្នុងលោកនេះ ដោយការលះបង់នូវអំពើសៅហ្មង ៤ យ៉ាង មិនធ្វើបាបកម្ម ព្រោះហេតុ ៤ យ៉ាង មិនសេពនូវអបាយមុខគឺប្រធាននៃសេចក្តីវិនាសនៃភោគៈ ៦ យ៉ាង ។*

***លះបង់អំពើសៅហ្មង ៤ យ៉ាងគឺ***

*១-មិនសម្លាប់សត្វ*

*២-មិនលួចទ្រព្យគេ*

*៣-មិនប្រព្រឹត្តខុសក្នុងកាម*

*៤-មិននិយាយកុហក*

***មិនធ្វើបាបកម្ម ព្រោះហេតុ ៤ យ៉ាងគឺ***

*១-ព្រោះស្រលាញ់*

*២-ព្រោះស្អប់*

*៣-ព្រោះល្ងង់*

*៤-ព្រោះខ្លាច*

***មិនសេពនូវអបាយមុខ ៦ យ៉ាងគឺ***

*១-ផឹកទឹកស្រវឹង*

*២-ដើរយប់ព្រលប់ខុសកាល*

*៣-ដើរមើលមហោស្រព*

*៤-លេងល្បែង*

*៥-សេពគប់មិត្រអាក្រក់*

*៦-ខ្ជិលច្រអូស*

ទោសផឹកទឹកស្រវឹងមាន ៥ យ៉ាង

១-វិនាសទ្រព្យ

២-នាំឲ្យមានជម្លោះ

៣-នាំឲ្យកើតរោគ

៤-នាំឲ្យខូចឈ្មោះ

៥-បង្ហាញកេរ្តិ៍ខ្មាស

៦-ធ្វើឲ្យបញ្ញាថយចុះ

ទោសដើរលេងយប់ព្រលប់ខុសកាល

១-មិនរក្សាខ្លួន

២-មិនរក្សាប្រពន្ធកូន

៣-មិនរក្សាទ្រព្យសម្បត្តិ

៤-សេចក្តីរង្កៀសតែងកើតមានក្នុងកន្លែងដែលខ្លួនទៅ

៥-ទទួលរងគ្រោះដោយគេចោទប្រកាន់

៦-ជាអ្នកសន្សំសេចក្តីទុក្ខច្រើន

ទោសដើរមើលល្បែង

១-របាំក្នុងទីណា ក៏ទៅទីនោះ

២-ចម្រៀងក្នុងទីណា ក៏ទៅទីនោះ

៣-ប្រគំក្នុងទីណា ក៏ទៅទីនោះ

៤-គេនិយាយរឿងឥតប្រយោជន៍ទីណា ក៏ទៅទីនោះ

៥-ល្បែងវាយគងទីណា ក៏ទៅទីនោះ

៦-ល្បែងវាយរនាតទីណា ក៏ទៅទីនោះ

ទោសអ្នកលេងល្បែងភ្នាល់

១-បើឈ្នះគេ តែងបានពៀរ

២-បើចាញ់គេ តែងសោកស្តាយទ្រព្យសម្បត្តិ

៣-វិនាសទ្រព្យសម្បត្តិ ដែលឃើញជាក់ស្តែងទាន់ភ្នែក

៤-កាលបើទៅសាលាវិនិច្ឆ័យ គេមិនជឿស្តាប់ពាក្យ

៥-ពួកមិត្រតែងបោះបង់ចោល

៦-ជាបុគ្គលដែលគេមិនដណ្តឹងឬឲ្យកូនស្រី

ទោសសេពគប់មិត្រអាក្រក់ តែងជួបមិត្រ

១-ជនដែលលេងល្បែងភ្នាល់

២-ជនដែលចូលចិត្តសប្បាយនឹងស្រីញី

៣-ជនដែលចូលចិត្តផឹកទឹកស្រវឹង

៤-ជនបោកប្រាសបញ្ឆោតអ្នកដទៃ

៥-ជនអ្នកកេងប្រវញ្ចទ្រព្យអ្នកដទៃ

៦-ជនអ្នកឆក់ដណ្តើមទ្រព្យអ្នកដទៃ

ទោសអ្នកប្រកបរឿយ ៗ នូវការខ្ជិលច្រអូសតែងមិនធ្វើការដោយអាងថា

១-ត្រជាក់ណាស់

២-ក្តៅណាស់

៣-ល្ងាចណាស់

៤-ព្រឹកណាស់

៥-ឃ្លានណាស់

៦-ស្រេកណាស់

មិត្តប្លមមាន ៤ យ៉ាងគឺ

១-មនុស្សគិតតែប្រយោជន៍ខ្លួន

២-មនុស្សល្អតែសំដី

៣-មនុស្សនិយាយចាក់បណ្តោយ

៤-មនុស្សជាសំឡាញ់ក្នុងការវិនាសទ្រព្យ

មនុស្សគិតតែប្រយោជន៍ខ្លួន ត្រូវស្គាល់ដោយស្ថាន ៤ គឺ

១-មិត្តគិតយកតែប្រយោជន៍ខ្លួន

២-មិត្តប្រាថ្នាយករបស់ច្រើន ដោយឲ្យរបស់តិច

៣-ទាល់តែមានភ័យទើបជួយធ្វើកិច្ចការរបស់មិត្ត

៤-សេពគប់មិត្តព្រោះហេតុតែប្រយោជន៍

មនុស្សល្អតែសំដី ត្រូវស្គាល់ដោយស្ថាន ៤ គឺ

១-មិត្តទទួលរាក់ទាក់របស់ដែលកន្លងទៅហើយ

២-ទទួលរាក់ទាក់របស់មិនទាន់មាន

៣-សង្គ្រោះអំពើឥតប្រយោជន៍

៤-កាលកិច្ចទាំងឡាយកើតភ្លាម ៗ អាងរបស់ខូចខាត

មនុស្សនិយាយចាក់បណ្តោយត្រូវស្គាល់ដោយស្ថាន ៤ គឺ

១-បើមិត្តធ្វើអំពើអាក្រក់ ក៏យល់ព្រមតាម

២-មិត្តធ្វើអំពើល្អ ក៏យល់ព្រមតាម

៣-ពណ៌នាគុណមិត្ត តែក្នុងទីចំពោះមិត្ត

៤-ពោលទោសមិត្តក្នុងទីកំបាំង

មនុស្សជាសំឡាញ់ក្នុងការវិនាសទ្រព្យត្រូវស្គាល់ដោយស្ថាន ៤ គឺ

១-មិត្រនាំផឹកទឹកស្រវឹង

២-មិត្រនាំដើរលេងខុសកាល

៣-មិត្រនាំដើរមើលមហោស្រព

៤-មិត្រនាំដើរលេងល្បែង

គប្បីសេពគប់មិត្រ ៤ ប្រភេទគឺ

១-មិត្រមានសន្តានល្អ

២-មិត្ររួមសុខទុក្ខ

៣-មិត្រប្រាប់ប្រយោជន៍

៤-មិត្រមានសេចក្តីឈឺឆ្អាល

មិត្រមានសន្តានល្អ ត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ

១-រក្សាមិត្រដែលធ្វេសប្រហែស

២-រក្សាសម្បត្តិរបស់មិត្រដែលធ្វេសប្រហែស

៣-ជាទីពឹងពំនាក់របស់មិត្រដែលមានកិតភ័យ

៤-កាលបើកិច្ចត្រូវកើតឡើងជួយភោគៈជាទ្វិគុណ

មិត្ររួមសុខទុក្ខ ត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ

១-ប្រាប់អាថ៌កំបាំងរបស់ខ្លួនដល់មិត្រ

២-ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្រ

៣-មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ

៤-សូម្បីជីវិតក៏ហ៊ានលះបង់ដើម្បីមិត្រ

មិត្តប្រាប់ប្រយោជន៍ ត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ

១-ហាមមិត្តមិនឲ្យធ្វើអំពើអាក្រក់

២-ដឹកនាំមិត្តឲ្យស្ថិតនៅក្នុងអំពើល្អ

៣-ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ

៤-ប្រាប់ផ្លូវស្ថានសួគ៌

មិត្តមានសេចក្តីឈឺឆ្អាល ត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ

១-ជួយព្រួយចិត្ត ព្រោះមិត្តបានសេចក្តីវិនាស

២-ជួយអរមិត្តព្រោះមិត្តបានចម្រើន

៣-ទទឹងទាស់មនុស្សដែលពោលទោសមិត្ត

៤-សរសើរមនុស្សដែលពោលគុណមិត្ត

ទិសខាងកើត: មាតាបិតាកូនត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាងគឺ

១-ចិញ្ចឹមមាតាបិតាវិញ

២-ជួយធ្វើការងារមាតាបិតា

៣-រក្សាវង្សត្រកូល

៤-ធ្វើខ្លួនឲ្យសមជាអ្នកទទួលមត៌ក

៥-ធ្វើបុណ្យឧទ្ទិសទក្ខិណាទាន ពេលគាត់ចែកឋាន

មាតាបិតាត្រូវអនុគ្រោះកូនដោយ ៥ យ៉ាងវិញគឺ

១-ហាមកូនចាកអំពើអាក្រក់

២-ឲ្យកូនតម្កល់នូវក្នុងអំពើល្អ

៣-ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ

៤-ដណ្តឹងភរិយា ស្វាមីសមគួរឲ្យ

៥-ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ

ទិសខាងត្បូង: សិស្សត្រូវប្រតិបត្តិគ្រូដោយស្ថាន ៥ យ៉ាងគឺ

១-ក្រោកឡើងទទួល

២-ដោយគាល់បម្រើ

៣-ជឿស្ដាប់ឱវាទ

៤-ជួយកិច្ចការផ្សេងៗ គ្រូបន្ទាប់បន្សំ

៥-យកចិត្តទុកដាក់រៀនសូត្រ ដោយគោរព

គ្រូត្រូវអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងវិញគឺ

១-ដឹកនាំល្អ

២-ឲ្យរៀនល្អ

៣-ប្រៀនប្រដៅសិស្សឲ្យចេះត្រឹមត្រូវក្នុងមុខវិជ្ជា

៤-លើកតម្កើងក្នុងទីប្រជុំ

៥-ធ្វើសេចក្ដីការពារក្នុងទិសទាំងឡាយ

ទិសខាងលិច: ស្វាមីត្រូវទំនុកបម្រុងភរិយាដោយស្ថាន ៥ យ៉ាងគឺ

១-ទុកជាភរិយាពេញទី

២-មិនមើលងាយភរិយា

៣-មិនក្បត់ចិត្តភរិយា

៤-ប្រគល់ការកិច្ចឲ្យជាធំក្នុងផ្ទះ

៥-ទិញគ្រឿងអលង្ការជូនភរិយាតាមកាលគួរ

ភរិយាត្រូវអនុគ្រោះស្វាមីដោយស្ថាន ៥ យ៉ាងវិញគឺ

១-ចាត់ចែងការងារផ្ទះដោយល្អ

២-សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ

៣-មិនក្បត់ចិត្តស្វាមី

៤-ថែទាំទ្រព្យសម្បត្តិគ្រួសារ

៥-ឈ្លាស មិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់

ទិសខាងជើង: មិត្រគឺខ្លួនត្រូវយកចិត្តទុកដាក់ដោយស្ថាន ៥ យ៉ាងគឺ

១-ដោយការឲ្យរបស់

២-ដោយនិយាយពាក្យគាប់ចិត្ត

៣-ដោយការប្រព្រឹត្តឲ្យជាប្រយោជន៍

៤-ដោយការប្រព្រឹត្តខ្លួនស្មើ

៥-មិនកុហកបញ្ឆោត

មិត្រដែលយកចិត្តទុកដាក់ យើងត្រូវអនុគ្រោះដោយស្ថាន ៥ យ៉ាងគឺ

១-រក្សាមិត្រដែលធ្វេសប្រហែស

២-ជួយថែទាំទ្រព្យរបស់មិត្រ ដែលធ្វេសប្រហែស

៣-ជាទីពឹងរបស់មិត្រដែលមានភ័យ

៤-មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ

៥-រាប់អានរហូតដល់ផៅពង្សរបស់មិត្រ

ទិសខាងក្រោម: ចៅហ្វាយនាយ ត្រូវទំនុកបម្រុងអ្នកក្រោមបង្គាប់ដោយស្ថាន ៥ គឺ

១-ចាត់ចែងការងារសមតាមកម្លាំង

២-ឲ្យភត្តាហារនិងថ្លៃឈ្នួល

៣-ព្យាបាលក្នុងវេលាឈឺថ្កាត់

៤-ចែករំលែករសត្រកាលចំឡែក

៥-ឲ្យឈប់សម្រាកក្នុងសម័យគួរ

អ្នកនៅខាងក្រោមបង្គាប់ ត្រូវអនុគ្រោះចៅហ្វាយនាយវិញគឺ

១-ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ

២-ឈប់ធ្វើការក្រោកចៅហ្វាយនាយ

៣-កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ

៤-ធ្វើការដោយយកចិត្តទុកដាក់

៥-ពោលសរសើរកិត្តិគុណចៅហ្វាយនាយ

ទិសខាងលើៈ សមណព្រាហ្មណ៍ (អ្នកបួស) យើងត្រូវផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាងគឺ

១-ដោយកាយកម្ម ប្រកបដោយមេត្តា

២-ដោយវចីកម្ម ប្រកបដោយមេត្តា

៣-ដោយមនោកម្ម ប្រកបដោយមេត្តា

៤-ជាអ្នកមិនបិទទ្វារផ្ទះ (ចេះធ្វើល្អចំពោះអ្នកមានសីល)

៥-ឲ្យអាមិសទាន គឺធ្វើទាន មានបាយ ទឹក សម្ភារៈជាដើម

សមណព្រាហ្មណ៍ ត្រូវអនុគ្រោះដោយស្ថាន ៥ យ៉ាងវិញគឺ

១-ហាមឃាត់ចាកអំពើបាប

២-ឲ្យតាំងនៅក្នុងអំពើល្អ

៣-អនុគ្រោះដោយចិត្តល្អ

៤-ឲ្យបានស្តាប់ធម៌ ដែលមិនបានស្តាប់

៥-ប្រាប់ផ្លូវសួគ៌

**ដោយលោកគ្រូធម្មានន្ទ**